ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

បេឡាជាតិសន្តិសុខសង្គម

លេខ :...០៣៤/...ប.ស.ស.
២៣

# សេចក្តីជូនដំណឹង
## ស្តីពី
## ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ
## អគារស្នាក់ការកណ្តាលបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.)
## នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ថ្ងៃព្រហស្បតិ៍ ៤រោច ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២៣ វេលាម៉ោងប្រាំបី និងសាមសិបនាទីព្រឹក បេឡាជាតិសន្តិសុខសង្គម បានរៀបចំពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគារស្នាក់ការកណ្តាល ប.ស.ស. មានអាស័យដ្ឋានភូមិបន្ទាស្អិត សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ដែលប្រព្រឹត្តទៅនៅសាលសន្តិភាពរបស់បេឡាជាតិសន្តិសុខសង្គម។ ក្នុងពីធីសម្ពោធដាក់ឱ្យប្រើប្រាស់អគារថ្មីនេះមានការអញ្ជើញចូលរួមក្រោមអធិបតីភាព ដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាតំណាងដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង **ឯកឧត្តមបណ្ឌិត អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាប្រធានក្រុមប្រឹក្សាភិបាលនៃ ប.ស.ស. ព្រមទាំង មានការអញ្ជើញ ចូលរួមពី ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី តំណាង ក្រសួង ស្ថាប័ន អង្គភាព និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធនានា ប្រមាណជា ៤០០នាក់។

បន្ទាប់ពីពិធីកាត់ខ្សែបូសម្ពោធអគារស្នាក់ការកណ្តាល ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលផ្តល់ជាកិត្តិយសដ៏ខ្ពង់ខ្ពស់ពីសំណាក់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រី នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីដាក់ឱ្យប្រើប្រាស់ជាផ្លូវការរួចមក ថ្លែងក្នុងពិធី **ឯកឧត្តមបណ្ឌិត អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាប្រធានក្រុមប្រឹក្សាភិបាលនៃ ប.ស.ស. បានជម្រាបជូន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** និងអង្គពិធីទាំងមូលថា អគារស្នាក់ការកណ្តាលថ្មីនេះមានកម្ពស់ ២១ជាន់ មានទំហំ ៥៤ ០០៣ម៉ែត្រក្រឡា នៅលើទីតាំងដី ដែលមានផ្ទៃក្រឡាសរុប ៣០ ៣១៣ម៉ែត្រក្រឡា ដើម្បីឱ្យស្របតាមកំណើន ទំហំការងារ ចំនួនមន្ត្រី និងបុគ្គលិក នាពេលបច្ចុប្បន្ន និងទៅអនាគត ព្រមទាំងអាចធានាបាននូវ ប្រសិទ្ធភាព និងប្រសិទ្ធផល ក្នុងការផ្តល់សេវាជូនសមាជិកខ្លួន។ អគារនេះត្រូវបានបំពាក់ដោយ ប្រព័ន្ធសុវត្ថិភាពអគ្គីភ័យ, ប្រព័ន្ធគ្រប់គ្រងអគារ, ប្រព័ន្ធត្រជាក់, ប្រព័ន្ធគ្រប់គ្រងទឹក, អគ្គីសនី, ប្រព័ន្ធគ្រប់គ្រងសាលប្រជុំ, ប្រព័ន្ធគ្រប់គ្រងទិន្នន័យ, គ្រឿងសង្ហារឹម និងហេដ្ឋារចនាសម្ព័ន្ធជុំវិញអគារ សួនរុក្ខជាតិ ព្រមទាំងផ្លូវបេតុងខាងមុខប្រវែង ១ ០៤០ម៉ែត្រ អស់ទឹកប្រាក់សរុបចំនួនប្រមាណជាង ៤៣លានដុល្លារអាមេរិក ដែលជាថវិកាបានពីការសន្សំរបស់ ប.ស.ស.



អាសយដ្ឋាន អាគារទីស្នាក់ការកណ្តាល បេឡាជាតិសន្តិសុខសង្គម ផ្លូវបេតុង សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ
ទូរស័ព្ទ: ០២៣ ២៦ ០០ ០១ , ០២៣ ៨៨ ១០ ១៥ / ០២៣ ៩៩ ៥២ ១៩ , ០២៣ ៨៨ ១០ ១៦
ទូរសារ : ០២៣ ៨៨ ២៦ ២៣ , ប្រអប់សំបុត្រ P.O.Box 70
Website : www.nssf.gov.kh

ផ្ទាល់។ អគារស្នាក់ការកណ្តាល ប.ស.ស. ដ៏ស្កឹមស្កៃនេះ ជាសមិទ្ធិផលថ្មីរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលបង្ហាញពីគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការអភិវឌ្ឍវិស័យសន្តិសុខសង្គមកាន់តែរឹងមាំ ទូលំទូលាយ ប្រកបដោយនិរន្តភាព ដើម្បីជាប្រយោជន៍ដល់កម្មករនិយោជិតទាំងសេដ្ឋកិច្ចក្នុងប្រព័ន្ធ និងសេដ្ឋកិច្ចក្រៅប្រព័ន្ធរួមទាំងប្រជាពលរដ្ឋ ដែលស្ថិតក្នុងវិសាលភាពនៃច្បាប់ស្តីពីរបបសន្តិសុខសង្គម។ អគារស្នាក់ការ ប.ស.ស. ដ៏ល្អនេះជាកេរ្តិ៍ដំណែលនៃសម័យតេជោសម្រាប់ជំនាន់ក្រោយប្រើប្រាស់ និងអភិវឌ្ឍបន្ត។

**ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី** ក៏បានលើកឡើងពីសារបានប្រព័ន្ធសន្តិសុខសង្គមចាប់តាំងពីចាប់បដិសណ្ឋិ រហូតដល់ការអនុវត្តប្រកបដោយភាពជោគជ័យ និងបានកំណត់ការគ្រប់គ្រងរបបសន្តិសុខសង្គមនៃព្រះរាជាណាចក្រកម្ពុជា គ្របដណ្តប់ទាំងវិស័យឯកជន និងវិស័យសាធារណៈ ដែលបានអនុវត្តរបបសន្តិសុខសង្គមចំនួន ៣រួមមាន៖ ទី១.ផ្នែកហានិភ័យការងារ ទី២.ផ្នែកថែទាំសុខភាព និងទី៣.ផ្នែកប្រាក់សោធន។ ជាមួយគ្នានេះ **ឯកឧត្តមបណ្ឌិត** បានលើកឡើងពីវឌ្ឍនភាពនៃការអនុវត្តរបបសន្តិសុខសង្គមដូចខាងក្រោម៖

❖ **របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ**

- វិស័យឯកជន អនុវត្តនៅខែវិច្ឆិកា ឆ្នាំ២០០៨
    - បានចុះបញ្ជី សហគ្រាស គ្រឹះស្ថាន ចំនួន ២២ ៩៣១ មានកម្មករនិយោជិត ២ ២៩៩ ៨០២ នាក់
    - ប្រមូលភាគទានពីនិយោជកសរុបបានចំនួនប្រមាណ ១ ០៧៤ពាន់ ២៤៦ លានរៀល (ស្មើនឹងប្រមាណ ២៦២លាន ១១ពាន់ដុល្លារអាមេរិក)
    - ចំណាយសរុបប្រមាណ ១៧៤ពាន់ ៨៧លានរៀល (ស្មើនឹងប្រមាណ ៤២ លាន ៤៦០ពាន់ដុល្លារអាមេរិក)
- វិស័យសាធារណៈ អនុវត្តនៅខែមករា ឆ្នាំ២០២១
    - បានចុះបញ្ជី ស្ថាប័ន ចំនួន ៣៥ មានសមាជិក ២២៩ ៤១៣នាក់
    - ទទួលភាគទានពីរាជរដ្ឋាភិបាលចំនួនប្រមាណ ៨ពាន់ ៣២១លានរៀល (ស្មើនឹងប្រមាណ ២លាន ២៩ពាន់ដុល្លារអាមេរិក)
    - ចំណាយសរុបប្រមាណ ៣៧៣លាន ៣៥៦ពាន់រៀល (ស្មើនឹងប្រមាណ ៩ម៉ឺន ៨១៨ពាន់ដុល្លារអាមេរិក)។

❖ **របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព**

- វិស័យឯកជន អនុវត្តនៅខែកញ្ញា ឆ្នាំ២០១៦
    - បានចុះបញ្ជី សហគ្រាស គ្រឹះស្ថាន ចំនួន ២២ ៩៣១ មានកម្មករនិយោជិត ២ ២៩៩ ៨០២ នាក់
    - ប្រមូលភាគទានពីនិយោជកសរុបបានចំនួនប្រមាណ ២ ២៤៣ពាន់ ៩៥២ លានរៀល (ស្មើនឹងប្រមាណ ៥៤៧លាន ១៨១ពាន់ដុល្លារអាមេរិក)។

- ចំណាយសរុបប្រមាណ ១ ៣៥១ពាន់ ៩៣៦លានរៀល (ស្មើនឹងប្រមាណ ៣២៩លាន ៧៩០ពាន់ដុល្លារអាមេរិក)។

- វិស័យសាធារណៈ អនុវត្តនៅខែមករា ឆ្នាំ២០១៨
  - បានចុះបញ្ជី សហគ្រាស គ្រឹះស្ថាន ចំនួន ៣៩ស្ថាប័ន មានសមាជិកចំនួន ៨៣៩ ២៨៣នាក់
  - ទទួលភាគទានពីរាជរដ្ឋាភិបាលចំនួនប្រមាណ ១៥២ពាន់ ៧៦៣លានរៀល (ស្មើនឹងប្រមាណ ៣៧លាន ២៥៩ពាន់ដុល្លារអាមេរិក)
  - ចំណាយសរុបប្រមាណ ១៨៤ពាន់ ៤៦៤លានរៀល (ស្មើនឹងប្រមាណ ៤៤ លាន ៩៩១ពាន់ដុល្លារអាមេរិក)។

❖ **របបសន្តិសុខសង្គមផ្នែកប្រាក់សោធនអនុវត្តនៅខែតុលា ឆ្នាំ២០២២**

- បានចុះបញ្ជី សហគ្រាស គ្រឹះស្ថាន ចំនួន ១៥ ៥៤៤ មានកម្មករនិយោជិត ២ ៦២៩ ៥៥៣ នាក់
- ប្រមូលភាគទានពីនិយោជក និងកម្មករនិយោជិតសរុបបានប្រមាណ ២៧៩ពាន់ ២៧៨លានរៀល (ស្មើនឹងប្រមាណ ៦៨លាន ៩៤០ពាន់ដុល្លារអាមេរិក)។

ក្រៅពីនេះប.ស.ស. មានភារកិច្ចត្រូវចូលរួមអនុវត្តនូវការផ្តល់ការថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល សម្រាប់កម្មករនិយោជិតក្រៅប្រព័ន្ធ និងការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រី នៅពេលសម្រាលកូនដែលបានចុះបញ្ជីកម្មករនិយោជិតក្រៅប្រព័ន្ធសរុប ៩២៦សហគ្រាស គ្រឹះស្ថាន មានសមាជិកសរុប ៩៨ ៩១៩នាក់ ក្នុងនោះមានក្រុមប្រឹក្សាឃុំ-សង្កាត់ និងមន្ត្រីភូមិ ៥៦ ៨៥២នាក់, កីឡាករ-កីឡាការិនី ១ ១៨៣នាក់, អ្នករត់រ៉ឺម៉កកង់បី, អ្នកធាក់ស៊ីក្លូ, អ្នករត់ម៉ូតូឌុប និងគោលដៅផ្សេងទៀត ៩១ ២៨៤នាក់។ ទន្ទឹមនឹងនេះបានបើកផ្តល់ថវិកាដល់កម្មការិនីសម្រាលកូន ៣៥៩ ៩១៤នាក់ ចំនួនកូន ៣៦២ ៣៨៩នាក់ ប្រាក់ឧបត្ថម្ភសរុប ១១៤ពាន់ ៩៥៥លាន ៦សែនរៀល។ នាពេលថ្មីៗនេះដែរ **សម្តេចតេជោ** បានសម្រេចផ្តល់អត្ថប្រយោជន៍បន្ថែមពីកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនកម្មករនិយោជិតស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ ចាប់ពីខែសីហា ឆ្នាំ២០២៣ តទៅ ដូចខាងក្រោម៖ មុនពេលសម្រាលកូន ទទួលបានប្រាក់ឧបត្ថម្ភចំនួន ៤លើក ដោយ ១លើក ទទួលបានចំនួន ៨ម៉ឺនរៀល។ ពេលសម្រាលកូន ទទួលបានប្រាក់ឧបត្ថម្ភ ដោយកូនចំនួន ១នាក់ ទទួលបានថវិកា ៨០ម៉ឺនរៀល, កូនភ្លោះ ២នាក់ ទទួលបានថវិកា ១លាន ២សែនរៀល, និងកូនភ្លោះ ៣នាក់ ទទួលបានថវិកា ១លាន ៦សែនរៀល និងទទួលបានថវិកាឧបត្ថម្ភបន្ថែមចំនួន ៥លានរៀល ពី **សម្តេចតេជោ** និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត**ផ្តល់។ ក្រោយពេលសម្រាលកូន ទទួលបានប្រាក់ឧបត្ថម្ភចំនួន ១០លើក ដោយ ១លើក ទទួលបានចំនួន ៨ម៉ឺនរៀល ក្នុងនោះ ៣លើក នៅពេលទៅទទួលសេវាពិនិត្យសុខភាពក្រោយពេលសម្រាលកូន និង ៧លើក នៅពេលយកកូនទៅទទួលថ្នាំបង្ការរហូតដល់អាយុ ២ឆ្នាំ។

ដោយឈរលើមូលដ្ឋានសមិទ្ធផលចម្បងៗ ដែលបានសម្រេចដោយជោគជ័យយ៉ាងគ្រជះគ្រចង់កន្លងមក ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានដាក់ទិសដៅជាយុទ្ធសាស្ត្រដូចខាងក្រោម ដើម្បីការចូលរួមចំណែកពង្រឹង និងពង្រីកប្រព័ន្ធគាំពារសង្គមដូចខាងក្រោម៖

- បន្តពង្រឹងប្រព័ន្ធសន្តិសុខសង្គមឱ្យកាន់តែរឹងមាំ តាមរយៈការពង្រឹងបេឡាជាតិសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បន្តអនុវត្តគោលនយោបាយតម្រូវ ឱ្យនិយោជកមានកាតព្វកិច្ចបង់ភាគទានជំនួសកម្មករនិយោជិត ១០០% សម្រាប់របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាព និងបន្តសិក្សាសមិទ្ធិលទ្ធភាពរៀបចំដាក់ឱ្យដំណើរការផ្នែកនិកម្មភាពការងារ
- បន្តអនុវត្តគោលនយោបាយរដ្ឋបង់ភាគទានជំនួសមន្ត្រីសាធារណៈ ចំពោះរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងផ្នែកប្រាក់សោធន និងបង់ជំនួសអតីតមន្ត្រីរាជការ និងអតីតយុទ្ធជនព្រមទាំងអ្នកនៅក្នុងបន្ទុកចំពោះរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព
- រៀបចំគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តដើម្បីពង្រីកវិសាលភាពនៃការអនុវត្តរបបសន្តិសុខសង្គមដល់សហគ្រិន និងកម្មករនិយោជិតនៃវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងអ្នកស្ម័គ្រចិត្តដទៃផ្សេងទៀត
- ជំរុញការរៀបចំលិខិតបទដ្ឋានគតិយុត្ត ដើម្បីពង្រីកការគ្របដណ្តប់របបសន្តិសុខសង្គម ដល់បុគ្គលក្នុងវិស័យសាធារណៈ បុគ្គលស្វ័យនិយោជន៍ និងអ្នកនៅក្នុងបន្ទុក
- ជំរុញការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងមន្ត្រីរបស់បេឡាជាតិសន្តិសុខសង្គម ក្នុងការសិក្សាគោលនយោបាយពាក់ព័ន្ធនឹងការអភិវឌ្ឍ និងពង្រីករបបសន្តិសុខសង្គម និងការរៀបចំផែនការវិនិយោគមូលនិធិសន្តិសុខសង្គម ដែលផ្តល់ផលប្រយោជន៍ដល់សមាជិកបេឡាជាតិសន្តិសុខសង្គម។

ក្នុងឱកាសនេះ **ឯកឧត្តមបណ្ឌិត** ក៏បានថ្លែងអំណរគុណចំពោះថ្នាក់ដឹកនាំ ក្រុមប្រឹក្សាភិបាលនៃ ប.ស.ស. គ្រប់ស្ថាប័នពាក់ព័ន្ធ ព្រមទាំងដៃគូអភិវឌ្ឍន៍ទាំងអស់ ដែលបានដឹកនាំ ផ្តល់នូវការណែនាំអនុវត្តភារកិច្ចការងារប្រកបដោយភាពជោគជ័យ និងចូលរួមយ៉ាងសកម្មក្នុងការផ្តល់កិច្ចសហការ និងការគាំទ្រដ៏មានតម្លៃរហូតធ្វើឱ្យ ប.ស.ស. សម្រេចលទ្ធផលជាទីមោទនៈនាពេលនេះ។

ក្នុងពិធីសម្ពោធអគារថ្មី ប.ស.ស. **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** បានមានប្រសាសន៍ពាក់ព័ន្ធគោលនយោបាយក្នុងការគ្រប់គ្រងស្ថានភាពកូវីដ-១៩ ការបំពេញតួនាទីជាប្រធានប្តូរវេន និងជាម្ចាស់ផ្ទះនៃកិច្ចប្រជុំកំពូលអាស៊ាន ការធ្វើជាម្ចាស់ផ្ទះរៀបចំព្រឹត្តិការណ៍កីឡាស៊ីហ្គេម ការស្តារ និងជំរុញសកម្មភាពសេដ្ឋកិច្ចឱ្យត្រឡប់ទៅរកភាពប្រក្រតីឡើងវិញបានយ៉ាងរហ័ស ដែលអនុញ្ញាតឱ្យរាជរដ្ឋាភិបាលដាក់ចេញនូវកម្មវិធីជាតិជំនួយសង្គមសំខាន់ៗរួមមាន៖ កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ, កម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍, កម្មវិធីអាហាររូបករណ៍ថ្នាក់បឋមសិក្សា និងមធ្យមសិក្សា សម្រាប់

កុមារមកពីគ្រួសារក្រីក្រ, កម្មវិធីរបបគោលនយោបាយសម្រាប់ជនពិការក្នុងសហគមន៍ និងកម្មវិធីសាច់ប្រាក់ពលកម្ម ជាមួយគ្នានេះដែរកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ រាជរដ្ឋាភិបាលកំពុងតែបន្តអនុវត្តនៅឡើយ។ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** ក៏បានបញ្ជាក់បន្ថែមពីការកសាងរចនាសម្ព័ន្ធប្រព័ន្ធគាំពារសង្គម និងការអនុវត្តប្រកបដោយជោគជ័យ តែយ៉ាងណាក៏មិនគួរមើលរំលងនូវបញ្ហាប្រឈម និងភាពខ្វះខាតមួយចំនួនដែលនៅសេសសល់ក្នុងនោះការគ្របដណ្តប់នៃប្រព័ន្ធសន្តិសុខសង្គម នៅតែជាបញ្ហាចម្បង ដែលរាជរដ្ឋាភិបាលនឹងដាក់ចេញនូវអន្តរាគមន៍មួយចំនួនដូចខាងក្រោម៖

១. កែសម្រួលកម្មវិធីឧបត្ថម្ភពេលសម្រាលកូន ជូនកម្មករនិយោជិតជាស្ត្រី និងមន្ត្រីសាធារណៈជាស្ត្រី ទៅជាកម្មវិធីឧបត្ថម្ភសាច់ប្រាក់ ក្នុងអំឡុងពេលមានផ្ទៃពោះ ពេលសម្រាល និងក្រោយសម្រាល រហូតដល់កូនមានអាយុ២ឆ្នាំ ដូចជាការអនុវត្តសម្រាប់ស្ត្រីមកពីគ្រួសារក្រីក្រមានប័ណ្ណសមធម៌ផងដែរ

២. ដាក់ឱ្យអនុវត្តនូវរបបថែទាំសុខភាព តាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល សម្រាប់បុគ្គលបម្រើការក្នុងសេវាកម្មដឹកជញ្ជូនទេសចរណ៍ នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ និង

៣. ដាក់ឱ្យដំណើរការនូវកម្មវិធីជំនួយសង្គមផ្នែកបណ្តុះបណ្តាលវិជ្ជាជីវៈ សម្រាប់យុវជនមកពីគ្រួសារក្រីក្រ។

បន្ថែមលើនេះ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** ក្នុងនាមជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម និងក្នុងនាម **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានផ្តល់នូវអនុសាសន៍មួយចំនួនដល់ ប.ស.ស. ដូចខាងក្រោម៖

១. ត្រូវបង្កើនប្រសិទ្ធភាព ក្នុងការផ្តល់សេវាជូនសមាជិករបស់ខ្លួន តាមរយៈការធ្វើឌីជីថលូបនីយកម្មនៃប្រព័ន្ធប្រតិបត្តិការរបស់ខ្លួន

២. ត្រូវបន្តពង្រឹងតម្លាភាព និងគណនេយ្យភាពស្ថាប័ន តាមរយៈការរៀបចំរបាយការណ៍ហិរញ្ញវត្ថុស្របតាមស្តង់ដា ដែលជាកម្មវត្ថុនៃការត្រួតពិនិត្យដោយ សវនករឯករាជ្យ និងដែលត្រូវបោះពុម្ពផ្សាយជាសាធារណៈ នាគ្រាបន្ទាប់

៣. ត្រូវសហការជាមួយក្រសួងសុខាភិបាល ដើម្បីពង្រឹងយន្តការតាមដានគុណភាពនៃការផ្តល់សេវារបស់មូលដ្ឋានសុខាភិបាលដែលជាដៃគូ

៤. ត្រូវសហការជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីបន្តជំរុញការចុះបញ្ជីក្រុមហ៊ុន ពិសេសសហគ្រាសធុនតូច និងមធ្យម ដើម្បីឱ្យកម្មករនិយោជិតនៃក្រុមហ៊ុនទាំងនោះអាចក្លាយជាសមាជិកនៃ ប.ស.ស. ស្របតាមបទប្បញ្ញត្តិជាធរមាន

៥. ត្រូវរៀបចំយន្តការដាក់ឱ្យដំណើរការនូវកម្មវិធីឧបត្ថម្ភសាច់ប្រាក់ ជូនកម្មករនិយោជិតជាស្ត្រីក្នុងអំឡុងពេលមានផ្ទៃពោះ ពេលសម្រាល និងក្រោយសម្រាលរហូតដល់កូនមានអាយុ ២ ឆ្នាំ

៦. ត្រូវចូលរួមអនុវត្តរបបថែទាំសុខភាព តាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាលសម្រាប់បុគ្គលបម្រើការក្នុងសេវាកម្មដឹកជញ្ជូនទេសចរណ៍នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ និង

៧. ត្រូវសហការជាមួយអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម ដើម្បីបន្តពិនិត្យលទ្ធភាពពង្រីកវិសាលភាពរបបសន្តិសុខសង្គម ទៅកាន់ពលរដ្ឋគោលដៅផ្សេងៗបន្ថែមទៀត ជាពិសេសអ្នកនៅក្នុងបន្ទុករបស់កម្មករនិយោជិត និងមន្ត្រីសាធារណៈ ព្រមទាំងពលរដ្ឋនៃវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ។

ជាថ្មីទៀត **ឯកឧត្តមអគ្គបណ្ឌិត សភាចារ្យ** មានប្រសាសន៍ថា អគារស្នាក់ការកណ្ដាលថ្មីរបស់ ប.ស.ស. នេះ នឹងរួមចំណែកក្នុងការបង្កើនប្រសិទ្ធភាព និងផ្ដល់ភាពងាយស្រួល ក្នុងការផ្ដល់សេវាជូនសមាជិក ប.ស.ស. ឱ្យបានកាន់តែប្រសើរបន្ថែមទៀត។ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** បានស្នើឱ្យថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិកទាំងអស់នៃ ប.ស.ស. យកចិត្តទុកដាក់ខ្ពស់ ក្នុងការថែទាំអគារថ្មីនេះ ឱ្យបានល្អ និងស្អាត សម្រាប់ប្រើប្រាស់យូរអង្វែងទៅអនាគត។ ក្នុងឱកាសនេះ **ឯកឧត្តមអគ្គបណ្ឌិត** ក៏បានថ្លែងអំណរគុណចំពោះថ្នាក់ដឹកនាំក្រសួង ថ្នាក់ដឹកនាំ ប.ស.ស. មន្ត្រី និងបុគ្គលិកគ្រប់ស្ថាប័នពាក់ព័ន្ធ ព្រមទាំងដៃគូអភិវឌ្ឍន៍ទាំងអស់ ដែលបានដឹកនាំ អនុវត្តភារកិច្ចការងារប្រកបដោយភាពជោគជ័យ និងចូលរួមយ៉ាងសកម្មក្នុងការផ្ដល់កិច្ចសហការ និងការគាំទ្រដ៏មានតម្លៃដើម្បីអភិវឌ្ឍន៍ប្រព័ន្ធសន្តិសុខសង្គមកម្ពុជា ឱ្យក្លាយជាប្រព័ន្ធមួយដែលមាន ប្រសិទ្ធភាព ចីរភាព ភាពធន់ សមធម៌ និង បរិយាប័ន្ន។

ចុងបញ្ចប់នៃពិធីសម្ពោធអគារថ្មីនេះ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** និង **ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី** បានផ្ដល់កិត្តិយសដ៏ខ្ពង់ខ្ពស់បំពាក់គ្រឿងឥស្សរិយយស និងមេដាយ ជូនថ្នាក់ដឹកនាំចំនួន ៥៣រូប ក្នុងនោះមេដាយជាតូបការចំនួន ៧រូប មេដាយព្រះរាជាណាចក្រកម្ពុជាថ្នាក់មហាសិរីវឌ្ឍន៍ចំនួន ៨រូប មេដាយសុវត្ថារាថ្នាក់មហាសិរីវឌ្ឍន៍ចំនួន ៥រូប មេដាយមុនីសារាភ័ណ្ឌថ្នាក់ធិបឌិន្ទចំនួន ៥រូប និងមេដាយមុនីសារាភ័ណ្ឌថ្នាក់អស្សប្ញទ្ធិចំនួន ២៨រូប។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃសុក្រ ៥កើត ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ២០២៣